ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ:.................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ«ការគ្រប់គ្រង ការតាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់»របស់ក្រសួងសាធារណការ និងដឹកជញ្ជូន(គណៈកម្មាធិការដឹកនាំត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់)




បញ្ជាក់៖
រង្វង់មូលលេខពណ៌ខៀវ គឺជាទីតាំងស្ថានីយជញ្ជីងថ្លឹងយានយន្តអចល័ត

ការិយបរិច្ឆេទ២០២២

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900
E-mail: naakh@naa.gov.kh website: www.naa.gov.kh

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ
# ក្រោមប្រធានបទ«ការគ្រប់គ្រង ការតាមដាន
# និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់»
# របស់ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការិយបរិច្ឆេទ២០២២

## សេចក្តីសង្ខេប

អនុលោមតាមមាត្រា២ និងមាត្រា៣ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិនឹងធ្វើសវកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ «ការគ្រប់គ្រង ការតាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់» របស់ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការិយបរិច្ឆេទ២០២២។ គោលបំណងនៃការធ្វើសវនកម្មដើម្បីធ្វើការវាយតម្លៃ ថាតើក្រសួងសាធារណការ និងដឹកជញ្ជូន បានអនុវត្តការពង្រឹងយន្តការនៃការគ្រប់គ្រង តាមដាន និងការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលដែរឬទេ?

វិស័យសាធារណការ និងដឹកជញ្ជូន ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាវិស័យអាទិភាព និងបានបន្តការគាំទ្រ បង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រកបដោយគុណភាព សម្រាប់បម្រើឱ្យការដឹកជញ្ជូនពហុរូបភាព គឺទាំងការដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក ផ្លូវសមុទ្រ កំពង់ផែ និងការដឹកជញ្ជូនតាមផ្លូវអាកាស ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ និងពិភពលោក។ កន្លងមកក្រសួងសាធារណការ និងដឹកជញ្ជូន បានពុះពារគ្រប់ការលំបាកក្នុងការធ្វើកំណែទម្រង់ ការគ្រប់គ្រងមន្ត្រីរាជការ ការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការកែទម្រង់ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងយានយន្ត ការគ្រប់គ្រងការងារដឹកជញ្ជូន និងការងារគ្រប់គ្រងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដោយសម្រេចបានលទ្ធផល និងសមិទ្ធផលល្អប្រសើរជាច្រើន ស្របតាមកម្មវិធីនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលតម្រូវឱ្យគ្រប់ក្រសួងស្ថាប័ន អនុវត្តការកែទម្រង់ស៊ីជម្រៅ ដោយជំរុញឱ្យមន្ត្រីបំពេញការងារផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពធ្វើយ៉ាងណា " **ធ្វើឱ្យបាន ធ្វើឱ្យរហ័ស និងធ្វើឱ្យមានតម្លាភាព** "។ ដើម្បីសម្រេចឱ្យបានគោលដៅ អនុវត្តតាមកម្មវិធីនយោបាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងស្របតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងសាធារណការ និងដឹកជញ្ជូន បានធ្វើការកែទម្រង់រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងរបស់ខ្លួន និងជាពិសេសបញ្ហាដែលប្រឈមជារៀងរាល់ឆ្នាំ បង្កឱ្យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់រងនូវការខូចខាតដែលធ្វើឱ្យខាតដល់ប្រយោជន៍សេដ្ឋកិច្ច សង្គម និងគោលនយោបាយរបស់ជាតិ បណ្តាលមកពីការ

ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដែលធ្វើឱ្យមានការចំណាយថវិកាជាតិយ៉ាងច្រើនទៅលើការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធទាំងនោះឡើងវិញ ក៏ដូចជាការជំរុញការអនុវត្តច្បាប់ស្ដីពីផ្លូវថ្នល់ (មាត្រា ២៦ និង មាត្រា៦០) ពាក់ព័ន្ធនឹងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ក្នុងន័យរួមចំណែកក្នុងការសន្សំសំចៃថវិកាជាតិ ព្រមទាំងធ្វើឱ្យប្រសើរឡើងដល់សុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក។ល។ ហេតុផលខាងលើ ទើបគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ហៅកាត់(គ.ត.ល.ទ) មួយត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៩ ដើម្បីដាក់ចេញនូវវិធានការទប់ស្កាត់រាល់ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ គ្រប់គ្រងស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសកម្រិតកំណត់ ស្ថិតនៅតាមបណ្ដាផ្លូវដែលគ្រប់គ្រងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ទប់ស្កាត់ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដោយសកម្មភាពការដឹកជញ្ជូនលើសកម្រិតកំណត់ និងការចាត់វិធានការក្នុងការបង្ក្រាប និងទប់ស្កាត់បទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ឱ្យបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ការប្រតិបត្តិលើកិច្ចប្រតិបត្តិការដំណើរការការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន នៅមានចំណុចខ្វះខាតមួយចំនួននៅឡើយដូចជា៖

១. ការពង្រឹងយន្តការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើការទប់ស្កាត់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅមានកម្រិត ដូចជា៖ កង្វះខាតការពង្រឹងអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការផ្សព្វផ្សាយ និងអប់រំច្បាប់ស្ដីពីផ្លូវថ្នល់ (មាត្រា២៦ និង មាត្រា៦០) កង្វះខាតការសិក្សាទីតាំង ការបង្កើតស្ថានីយថ្លឹងយានយន្ត និងការចាត់វិធានការលើទីតាំងយានដ្ឋានជួសជុល កែច្នៃ និងដំឡើងយានយន្ត។

២. ការពង្រឹងយន្តការ វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅមានកម្រិត ដូចជា៖ កង្វះខាតយន្តការ និងវិធានការតឹងរ៉ឹងចំពោះយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ កង្វះខាតយន្តការនៃការគ្រប់គ្រងប្រព័ន្ធរក្សាទិន្នន័យ កត់ត្រាតាមដានប្រវត្តិយានយន្តនៅតាមស្ថានីយថ្លឹងយានយន្តលើសទម្ងន់កម្រិតកំណត់។

៣. ការតាមដាន និងការត្រួតពិនិត្យនៅតាមស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅមានកម្រិត ដូចជា៖ កង្វះខាតក្នុងការកត់ត្រាតាមដានសកម្មភាពប្រចាំថ្ងៃរបស់ស្ថានីយជញ្ជីង និងការថែទាំជញ្ជីងថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

ឆ្លងតាមលទ្ធផល និងសេចក្ដីសន្និដ្ឋាននៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ "ការគ្រប់គ្រង ការតាមដាន និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់" នៅក្រសួងសាធារណការ និងដឹកជញ្ជូន។ អាជ្ញាធរសវនកម្មជាតិសូមផ្ដល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. ក្រសួងសាធារណការ និងដឹកជញ្ជូន គួរជំរុញអង្គភាពពាក់ព័ន្ធអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសាធារណការដឹកជញ្ជូន លើការទប់ស្កាត់បទល្មើសយានយន្តដឹកជញ្ជូន

លើសទម្ងន់កម្រិតកំណត់ ដូចជា៖ ការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ការសិក្សាទីតាំង និងការបង្កើតស្ថានីយថ្លឹងយានយន្តដែលធ្វើឱ្យយានយន្តដឹកលើសទម្ងន់មិនអាចគេចពីស្ថានីយជញ្ជីង ការជំរុញការចុះត្រួតពិនិត្យ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដល់ម្ចាស់យានដ្ឋានជួសជុលកែច្នៃ និងដំឡើងយានយន្ត ក្នុងការចូលរួមចំណែកការទប់ស្កាត់រថយន្តដឹកទំនិញខុសស្តង់ដាបច្ចេកទេសដើម្បីធានាបានប្រសិទ្ធភាព។

២. ក្រសួងសាធារណការ និងដឹកជញ្ជូន គួរជំរុញគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពពាក់ព័ន្ធ ពង្រឹងវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់បន្ថែមទៀត ដើម្បីធានាឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីផ្លូវថ្នល់។

៣. ក្រសួងសាធារណការ និងដឹកជញ្ជូន គួរជំរុញគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពពាក់ព័ន្ធ តាមដានការអនុវត្តភារកិច្ចរបស់ក្រុមហ៊ុនផ្គត់ផ្គង់សេវាថែទាំជញ្ជីងថ្លឹងយានយន្ត (ក្រុមហ៊ុនអេអេភីគ្រុប) ឱ្យធ្វើតារាងតម្លៃ តារាងអាទិភាពគ្រឿងបន្លាស់ពាក់ព័ន្ធទៅតាមបរិមាណ និងពេលវេលាកំណត់ដើម្បីមានមូលដ្ឋានសម្រាប់ការគ្រោងបំរុងការថែទាំ និងជួសជុលធានាបាននៅប្រសិទ្ធភាព។

**មតិរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យរដ្ឋបាល**
**ចូល**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខៈ ៦២៣៣ សក.សជក ថ្ងៃព្រហស្បតិ៍ ៣រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

**សូមគោរពជូន**
**លោកជំទាវ អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ**

**កម្មវត្ថុ៖** ស្ដីពីការឆ្លើយបំភ្លឺ ចំពោះរបាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ "ការគ្រប់គ្រង ការតាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់"របស់ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការិយបរិច្ឆេទ២០២២។

**យោង** ៖ លិខិតលេខ០៧៧/២៣ អសជ/សណាធ ចុះថ្ងៃ២៥ ខែធ្នូ ឆ្នាំ២០២៣ របស់អាជ្ញាធរសវនកម្មជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកជំទាវ អគ្គសវនករ** មេត្តាជ្រាបថា ក្រសួងសាធារណការ និងដឹកជញ្ជូនសូមឆ្លើយបំភ្លឺចំពោះរបាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ "ការគ្រប់គ្រង ការតាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់" របស់ក្រសួងសាធារណការ និងដឹកជញ្ជូនសម្រាប់ការិយបរិច្ឆេទ២០២២ ថា ក្រសួង សូមឯកភាពនឹងលទ្ធផលសវនកម្មដែលបានសង្កេតឃើញ និងខិតខំអនុវត្តតាមអនុសាសន៍សវនកម្ម ដោយណែនាំគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ឱ្យអនុវត្ត ដូចតទៅ៖

- ខិតខំអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ពង្រឹងការអនុវត្តតាមច្បាប់ បទដ្ឋានគតិយុត្តនានា ផ្សព្វផ្សាយចែកខិត្តប័ណ្ណនៅតាមគោលដៅសំខាន់ៗ
- បង្កើនស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដោយសហការជាមួយភាគីពាក់ព័ន្ធដើម្បីស្វែងរកទីតាំងសមស្រប
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីមានវិធានការផ្លូវច្បាប់សមស្របចំពោះយានដ្ឋានជួសជុល កែច្នៃ និងដំឡើងយានយន្តណាដែលមិនស្របច្បាប់ និងបទដ្ឋានគតិយុត្តនានា
- ពង្រឹងការអនុវត្តយន្តការ និងវិធានការតឹងរ៉ឹងចំពោះយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ រួមទាំងការពិន័យអន្តរការណ៍
- ពង្រឹងការគ្រប់គ្រង កត់ត្រា និងរក្សាទុកទិន្នន័យយានយន្តដែលបានដឹកលើសកម្រិតកំណត់ ដើម្បីតាមដានប្រវត្តិយានយន្តនោះ
- ណែនាំស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ឱ្យកត់ត្រាសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន បន្ថែមពីលើការរាយការណ៍តាមប្រព័ន្ធTelegram ដែលកំពុងអនុវត្ត
- ពង្រឹងកិច្ចថែទាំជញ្ជីងថ្លឹងយានយន្តតាមស្ថានីយនានា។

អាស្រ័យដូចបានរៀបរាប់ខាងលើ សូម **លោកជំទាវ អគ្គសវនករ** មេត្តាជ្រាបជាព័ត៌មានសម្រាប់រៀបចំរបាយការណ៍សវនកម្មចុងក្រោយ។

សូម **លោកជំទាវ អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ប៉េង ពោធិ៍នា**